សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ២២៩
ចុះថ្ងៃទី១៣-០៣-២០១៥
សាលដីកា
លេខ: ៩៥ ត្រ IV សស
ចុះថ្ងៃទី០៤.០៩.២០១៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

16/11/2015

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បានបង្កើតឡើងតាមច្បាប់ ស្តីពីការរៀបចំអង្គការតុលាការដែលប្រកាសឲ្យប្រើតាមតាមព្រះរាជក្រមលេខ នស/រកម/០៧១៨/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៨ ។ [redacted]

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៥ដោយមានសមាសភាពចូលរួមដូចតទៅ៖

**<u>សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ</u>**

- លោក [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

- លោក [redacted]

**<u>ក្រឡាបញ្ជី</u>**

- លោក [redacted]

*ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ២២៩ ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ២០១៥ ដែលមាន ៖*

១.ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ មុខរបរ រត់ម៉ូតូឌុប ទីកន្លែងកំណើតនៅភូមិប៉លារ ឃុំពោធិ៍រំចាក់ ស្រុកព្រៃកប្បាស ខេត្តតាកែវ មានទីលំនៅមុនពេលឃុំខ្លួននៅភូមិស្រម៉លារ ឃុំពោធិ៍រំចាក់ ស្រុកព្រៃកប្បាស ខេត្តតាកែវ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន០៤នាក់ ។ (ដើមបណ្តឹងឧទ្ធរណ៍)

-ឃុំខ្លួនលេខ ៨១៨ ត.ប្រ ចុះថ្ងៃទី០២ ខែមិនា ឆ្នាំ២០១៨ ។

២.ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ មុខរបរយោធា ទីកន្លែងកំណើតនៅភូមិព្រៃស្បែង ឃុំពោធិ៍ចំរើន ស្រុកសេដ្ឋ ខេត្តកំពង់ស្ពឺ មានទីលំនៅមុនពេលឃុំខ្លួននៅផ្ទះជួល ៣៨៧E3Z ភូមិ៩ សង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] ាសពីមុនគ្មាន ។ (ដើមបណ្តឹងឧទ្ធរណ៍) [redacted]



p

Scanned by CamScanner

-(ឃុំខ្លួនលេខ ៨១៥ ត.ព្រ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨) ។

៣.ជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ មុខរបរស៊ីឈ្នួលតាមផ្ទះ ទីកន្លែងកំណើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ មានទីលំនៅមុនពេលឃុំខ្លួននៅផ្ទះជួល ៤៩ D ភូមិ១ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]) ម្តាយឈ្មោះ [redacted] (ស) ប្តីឈ្មោះ [redacted] ទោសពីមុនគ្មាន ។ (ដើមបណ្តឹងឧទ្ធរណ៍)

-(ឃុំខ្លួនលេខ ៨១៦ ត.ព្រ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨) ។

៤.ជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ២០ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ ទីកន្លែងកំណើតនៅភូមិព្រែកប្រា សង្កាត់ព្រែកប្រា ខណ្ឌមានជ័យ រាជធានីភ្នំពេញ មានទីលំនៅមុនពេលឃុំខ្លួននៅផ្ទះជួល ៤៩ D ភូមិ១ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]) ម្តាយឈ្មោះ [redacted]) នៅលីវ ទោសពីមុនគ្មាន ។ (ដើមបណ្តឹងឧទ្ធរណ៍)

-(ឃុំខ្លួនលេខ ៨១៨ ត.ព្រ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨) ។

៥.ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ១៧ឆ្នាំ ជាតិខ្មែរ មុខរបរសិស្ស ទីកន្លែងកំណើតនៅភូមិផ្សារថ្មី ឃុំពាមប្រធ្លោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម មានទីលំនៅមុនពេលឃុំខ្លួននៅផ្ទះជួល ៤៩ D ភូមិ១ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]) ម្តាយឈ្មោះ [redacted]) នៅលីវ ទោសពីមុនគ្មាន ។ (ដើមបណ្តឹងឧទ្ធរណ៍)

-(ឃុំខ្លួនលេខ ៨១៩ ត.ព្រ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨) ។

ជាប់ចោទពីបទ៖ ជួញដូរនិងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅផ្ទះជួល ៤៩ D ភូមិ១ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**៦រឿងហេតុមានដូចតទៅ**

កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង១១ និង ៤៥នាទី កំលាំងសមត្ថកិច្ចនៃការិយាល័យប្រឆាំងគ្រឿងញៀនរាជធានីភ្នំពេញ បានធ្វើការចុះបង្ក្រាបករណីជួញដូរ និងប្រើប្រាស់គ្រឿងញៀនតាមដីកាឆែកឆេរលេខ ០៥០/១៨ បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញនៅចំណុចផ្ទះជួល ៤៩ D ភូមិ១ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ដោយឃាត់ខ្លួនបានជនសង្ស័យឈ្មោះ [redacted] ហៅ [redacted] ,ឈ្មោះ [redacted] ,ឈ្មោះ [redacted] ,ឈ្មោះ [redacted] ,ឈ្មោះ [redacted] ឈ្មោះ [redacted] និងឃាត់ខ្លួនឈ្មោះ [redacted] ហៅ [redacted] ហៅ [redacted] ខណៈពេលដែលជនទាំងនេះទើបតែបានប្រើ



Scanned by CamScanner

ប្រាស់ថ្នាំញៀនរួច ចំណែកឯឈ្មោះ[redacted]និងឈ្មោះ[redacted]បានរត់គេខ្លួនបាត់ ហើយនៅក្នុងការចុះបង្ក្រាបនោះ សមត្ថកិច្ចបានធ្វើការឆែកឆេរ និងដកហូតបាននូវក្រាមពណ៌សថ្លា ចំនួន ១០កញ្ចប់ ថង់ធំ ០២ និងថង់តូច១០៨ សរុបទម្ងន់២៨៨,១៨ ក្រាម , ថ្នាំគ្រាប់ពណ៌ផ្កាឈូកចំនួន១៣២ គ្រាប់ សរុបទម្ងន់ ១២,៨៥ ក្រាម , ម្សៅពណ៌សម៉ត់ចំនួន ០១កូនកញ្ចប់ សរុបទម្ងន់ ២,៧៨ក្រាម , ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន០៦ ឧបករណ៍ប្រើប្រាស់គ្រឿងញៀនចំនួន០៥ ព្រមទាំងសំភារៈពាក់ព័ន្ធផ្សេងៗ ទៀត ដោយឧបករណ៍ប្រភេទ SIMON TEST ហើយជាលទ្ធផលតេស្តបង្ហាញថា ក្រាមសថ្លា និងថ្នាំគ្រាប់ពណ៌ផ្កាឈូកមានចេញពណ៌ខៀវមានសារធាតុញៀនប្រភេទមេតំហ្វេតាមីន ចំណែកម្សៅពណ៌សម៉ត់ពុំមានប្រតិកម្មជាមួយឧបករណ៍តេស្តឡើយ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ២១៨ ក្រ៨ (ក) ក.ព.ព្រ.ទ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនឹងសេចក្តីសម្រេចដូចខាងក្រោម៖

១.ផ្តន្ទាទោស៖

ក.ឈ្មោះ[redacted]ភេទស្រី អាយុ ៣៧ឆ្នាំ

ខ.ឈ្មោះ [redacted]ភេទប្រុស អាយុ ៤២ឆ្នាំ

ដាក់ពន្ធនាគារកំណត់រយៈពេលម្នាក់ៗ១៥ឆ្នាំ និងពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន ៥.០០០.០០០ (ប្រាំលានរៀល) ។

២.ផ្តន្ទាទោសឈ្មោះ៖

ក.ឈ្មោះ [redacted]ភេទប្រុស អាយុ៣៧ឆ្នាំ

ខ.ឈ្មោះ [redacted]ភេទស្រី អាយុ២២ឆ្នាំ

គ.ឈ្មោះ[redacted]ភេទស្រី អាយុ២០ឆ្នាំ

ដាក់ពន្ធនាគារកំណត់ម្នាក់ៗចំនួន១០ឆ្នាំ និងពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន ៥.០០០.០០០(ប្រាំលានរៀល) ។

៣.ផ្តន្ទាទោសឈ្មោះ[redacted]ភេទប្រុស អាយុ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន៧ឆ្នាំ និងពិន័យជាប្រាក់៥លានរៀល ។

ពីបទ៖ ជួញដូរ នឹង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅផ្ទះផ្លូវ ៤៩ D ភូមិ១ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤.វត្ថុចាប់យកដូចមានក្នុងកំណត់ហេតុទទួលវត្ថុតាង របស់ចៅក្រមស៊ើបសួរលេខ ១៧៧ ត.វ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៨ រួមមាន៖

-ស្រោមសំបុត្រពណ៌សដែលផ្ទុកគ្រឿងញៀនប្រភេទមេតំហ្វេតាមីនបិតជិត



Scanned by CamScanner

-ឧបករណ៍សម្រាប់ប្រើប្រាស់គ្រឿងញៀនមួយចំនួន

-ជញ្ជីងថ្លឹងគ្រឿងញៀនចំនួន០១

-ក្ចនថង់ប្លាស្ទិចមួយចំនួន

-សៀវភៅបញ្ជីអ្នកជំពាក់លុយថ្លៃគ្រឿងញៀនចំនួន ០១ក្បាល ត្រូវរឹបអូសតាមមាត្រា ៦២,៦៣ នៃក្រមព្រហ្មទណ្ឌ ។

-អាវុធខ្លីម៉ាក CSZ92-9 មួយដើម គ្រាប់ចំនួន០៤ និងបង់មួយ

-កាបូបចំនួន០៣ (កាបូបលុយចំនួន០២ និងកាបូបធំពណ៌ខ្មៅធំចំនួន០១)

-ទូរស័ព្ទដៃចំនួន០៦គ្រឿង (ម៉ាកណូគាចំនួន០៥គ្រឿង ខ្មៅ០៣គ្រឿង ស១គ្រឿង មិត្តហ្វូនចំនួន០១គ្រឿង) ។

-ប្រាក់ដុល្លាចំនួន១០០ដុល្លា

-ប័ណ្ណសំគាល់អាវុធខ្លីលេខ ត.១០៨៥២ កពជ របស់ក្រសួងការពារជាតិចំនួន០១សន្លឹក ។

-អត្តសញ្ញាណប័ណ្ណនាយទាហានរង ពលទាហានលេខ ៩ស១១ជ ៦៨៧៦ របស់ឈ្មោះ អ៊ែល សារីន ចំនួន០១ច្បាប់

-លិខិតបញ្ជាបេសកម្ម បញ្ជាការដ្ឋានកាំភ្លើងធំលេខ ០៣៨/១៤ ក.ភ.ធ

-រថយន្តម៉ាក REV-4 ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ ២B-3923 ចំនួន០១គ្រឿង

-ខ្សែដៃលោហៈធាតុពណ៌ស្លេកចំនួន០១ល្បៀង (ប្រហែលកាឡៃ)

-ខ្សែកលោហៈពណ៌ស្លេកចំនួន ០២ល្បៀង (ប្រហែលកាឡៃ)

-បណ្តោងលោហៈធាតុពណ៌ល្បៀងស្លេក មានដាំត្បូងសតូចៗ ចំនួន០១ (ប្រហែលកាឡៃ)

-ក្រវិលលោហៈធាតុពណ៌សចំនួន០១ ចំហៀង(ប្រហែលកាឡៃ)

-ត្បូងពណ៌សគ្រាប់ធំចំនួន០១គ្រាប់, បន្ទោរ០១គ្រាប់ និងតូចចំនួន០៥គ្រាប់ និងត្បូងពណ៌ក្រហមចំនួន០៤គ្រាប់ (គ្រាប់ធំចំនួន០២គ្រាប់ ,គ្រាប់តូចចំនួន០២គ្រាប់) ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ តាមមាត្រា៣៥៤ នៃក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៤ និងប្រកាសជាធារណៈថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ចំពោះមុខជនជាប់ចោទ ។ ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍៧៣០ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted]សុំប្តឹងឧទ្ធរណ៍ និងសាលក្រមព្រហ្មទណ្ឌលេខ ២១៤ ក្រ៥ "ក" ភ.ព.ព្រ.ទ ចុះថ្ងៃ១៧ ខែតុលា ឆ្នាំ២០១៤ ក្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។



Scanned by CamScanner

-បានឃើញសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ៧៥០ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] តែបានដកបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៥ វិញ ) ។

-បានឃើញសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍៧៣៣ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] សុំប្តឹងឧទ្ធរណ៍ និងសាលក្រមព្រហ្មទណ្ឌលេខ ២១៤ ក្រ៨ "ភ" ភ.ព.ព្រ.ទ ចុះថ្ងៃ១៧ ខែតុលា ឆ្នាំ២០១៤ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

-បានឃើញសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍៧៣៤ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] សុំប្តឹងឧទ្ធរណ៍ និងសាលក្រមព្រហ្មទណ្ឌលេខ២១៤ ក្រ៨ "ភ" ភ.ព.ព្រ.ទ ចុះថ្ងៃ១៧ ខែតុលា ឆ្នាំ២០១៤ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

-បានឃើញសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍៧៤៩ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] សុំប្តឹងឧទ្ធរណ៍ និងសាលក្រមព្រហ្មទណ្ឌលេខ២១៤ ក្រ៨ "ភ" ភ.ព.ព្រ.ទ ចុះថ្ងៃ១៧ ខែតុលា ឆ្នាំ២០១៤ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

-បានឃើញសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍៧៥១ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] សុំប្តឹងឧទ្ធរណ៍ និងសាលក្រមព្រហ្មទណ្ឌលេខ ២១៤ ក្រ៨ "ភ" ភ.ព.ព្រ.ទ ចុះថ្ងៃ១៧ ខែតុលា ឆ្នាំ២០១៤ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

-បានឃើញ របាយការណ៍រឿងព្រហ្មទណ្ឌ របស់ចៅក្រមរបាយការណ៍នៃសាលាឧទ្ធរណ៍ ។

-បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

<u>**នាពេលសវនាការ**</u>

-ជនជាប់ចោទឈ្មោះ [redacted] ឆ្លើយថា៖បានជាខ្ញុំប្តឹងមកសាលាឧទ្ធរណ៍ ដោយសាលាដំបូងរាជធានីភ្នំពេញ សម្រេចដាក់ទោសខ្ញុំច្រើនពេក ។ ខ្ញុំរត់ម៉ូតូឌុប ឈ្មោះ [redacted] ឲ្យខ្ញុំទៅយកឥវ៉ាន់ពីឈ្មោះ [redacted] នៅមុខផ្សារពោធិ៍ចិនតុង ដោយឲ្យតំលៃឈ្នួលម្តង១០០០០ (មួយម៉ឺនរៀល) ខ្ញុំទៅយកបានបីដង ខ្ញុំមិនដឹងថាទៅយកគ្រឿងញៀននោះទេ ឃើញគេដាក់ថង់ស្ពានតែនំ សំណូមពរសុំបន្ធូរបន្ថយទោសដល់រូបខ្ញុំ ។

-ជនជាប់ចោទឈ្មោះ [redacted] ឆ្លើយថា៖ថ្ងៃកើតហេតុឈ្មោះ [redacted] បានប្រាប់ខ្ញុំថានៅផ្ទះប្រពន្ធខ្ញុំសមត្ថកិច្ចបានចុះឆែកឆេរ និងចាប់អតីតប្រពន្ធខ្ញុំ ខ្ញុំរួមជូនឈ្មោះក៏បានទៅទីនោះ ដើម្បីយកកូន ព្រោះទំលាប់ខ្ញុំពីរបីថ្ងៃខ្ញុំទៅមើលកូនម្តង ។ ខ្ញុំសូមបញ្ជាក់ថា



Scanned by CamScanner

ខ្ញុំ និងប្រពន្ធឈ្មោះ [redacted] បានលែងលះគ្នាតាំងតែពីកូនខ្ញុំនៅក្នុងពោះម្ដេះ ដោយសារប្រពន្ធខ្ញុំលាក់បាំងនឹងខ្ញុំ ទះធ្វើរកស៊ីរបស់គាត់ ខ្ញុំធ្លាប់ឃើញកញ្ចប់សម្លងដែរ តែមិនដឹងថាគ្រឿងញៀនទេ ពេលសមត្ថកិច្ចចាប់ខ្ញុំពេលដែលខ្ញុំទៅយកកូន គេបាន ឆែកឆេរទីនោះ រួចហើយទើបខ្ញុំដើរចូលទៅតាមក្រោយ សមត្ថកិច្ចចាប់ខ្ញុំតែម្ដង ខ្ញុំពុំ ដែលបានរកស៊ីជួញដូរគ្រឿងញៀន ឬរួមគំនិតជាមួយប្រពន្ធទេ ព្រោះបែកគ្នាយូរ ហើយ ខ្ញុំមករស់នៅជាមួយម្ដាយ ។ សំណូមពរសុំលើកលែងចោទប្រកាន់លើខ្ញុំ ។

-ជនជាប់ចោទឈ្មោះ [redacted] ឆ្លើយថា៖ខ្ញុំជាអ្នកមើលកូនឲ្យឈ្មោះ [redacted] ដោយក្នុងមួយសប្ដាហ៍គាត់ឲ្យខ្ញុំ១០ដុល្លា ទៅ២០ដុល្លា ខ្ញុំធ្លាប់ជក់គ្រឿង ញៀនតែមិនបានទិញ និងជក់ក្នុងផ្ទះ [redacted] ទេ ខ្ញុំទិញពីទួលគោក ពីក្មេងៗទៅ ជក់នៅផ្ទះខ្ញុំផ្ទាល់ ខ្ញុំស្គាល់ឈ្មោះ [redacted] យៈពេលប្រហែល៥,៦ ខែ គាត់មិន ដែលចេញទៅណាទេ ខ្ញុំធ្លាប់ឃើញឈ្មោះ [redacted] ចេញចូលកាន់កញ្ចប់ៗកញ្ចប់ មិនដឹងអ្វីទេ ហើយក៏ឧស្សាហ៍ឃើញមនុស្សចេញចូលដែរ ។ ចំណែកឈ្មោះ [redacted] ខ្ញុំមិនធ្លាប់ជួបទេ ខ្ញុំពុំបានប្រព្រឹត្តបទចោទប្រកាន់ទេ ។ សំណូមពរសុំលើកលែង ទោសដល់រូបខ្ញុំ ។

-ជនជាប់ចោទឈ្មោះ [redacted] ឆ្លើយថា៖ខ្ញុំមករស់នៅផ្ទះ [redacted] ដើម្បី មើលកូនឲ្យគាត់ដោយគាត់ឲ្យកម្រៃមួយអាទិត្យ២០ដុល្លា ទៅ៣០ដុល្លា ខ្ញុំធ្លាប់ជក់ គ្រឿងញៀន នៅផ្ទះ [redacted] ដោយទិញពីឈ្មោះ [redacted] ពេលខ្ញុំជក់មិន អស់មិត្តភ័ក្រសុំចែកខ្ញុំក៏លក់ឲ្យវិញទៅ កន្លងមកធ្លាប់យកគ្រឿងញៀនពី [redacted] ទៅលក់បានពីរបីដង ចំណេញ១០ដុល្លា ទៅ២០ដុល្លា ។ សំណូមពរសុំបន្ធូរបន្ថយ ទោស ។

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា៖ខ្ញុំជាក្មួយរបស់ឈ្មោះ [redacted] ខ្ញុំធ្លាប់យកថ្នាំញៀនពីគាត់ទៅលក់ឲ្យគេពីរបីដងបានចំណេញពី ១០ដុល្លា ទៅ២០ដុល្លា ខ្ញុំធ្លាប់ស្គាល់ឈ្មោះ [redacted] និង [redacted] ព្រោះគាត់នៅមើកូនឲ្យមីងខ្ញុំ [redacted] ខ្ញុំមិនដែលឃើញទេ ចំណែក [redacted] ឃើញពេលគេឆែកឆេរផ្ទះ សំណូមពរសុំបន្ធូរបន្ថយទោស ។

តំណាងមហាអយ្យការធ្វើសេចក្ដីសន្និដ្ឋាន

សុំប្រធានក្រុមប្រឹក្សា វែកញែកអង្គហេតុលើជនជាប់ចោទឲ្យមានសមធម៌ឡើង វិញ គ្រឿងញៀនដកហូតមានទំងន់សរុបជាង២៨០ក្រាម និងមានជញ្ជីងសំរាប់ថ្លឹង ដើម្បីលក់ដូរ តែឈ្មោះ [redacted] និង [redacted] គ្រាន់តែអ្នកយកគ្រឿងញៀននោះ លក់បន្តិចបន្តួច ព្រោះការផ្ដន្ទាទោសមានលក្ខណៈធ្ងន់ធ្ងរណាស់លើអ្នកទាំងបីនេះ ។ ចំពោះជនជាប់ចោទឈ្មោះ [redacted] គ្មានលិខិតបញ្ជាក់លែងលះប្រពន្ធ [redacted] ឲ្យបានច្បាស់លាស់ ដែលជាកស្តុតាងដោះបន្ទុកនោះទេ [redacted] រកស៊ុ



Scanned by CamScanner

គ្រឿងញៀនយូរឆ្នាំហើយ ប្តីប្រពន្ធពិតជាបានរួមគំនិតគ្នា [redacted] ទោះបីពុំសារភាពក៏ដោយមានភស្តុតាងដាក់បន្ទុក ព្រោះចម្លើយរបស់ [redacted] ថា គ្រឿងញៀន និងជញ្ជីងថ្លឹងគឺរបស់ [redacted] ហើយថាយកឥវ៉ាន់៣ដងពីទីនោះ គឺគ្រឿងញៀន ។ ក្នុងពេលសម្រេចសេចក្តីសុំបញ្ចូលលទ្ធផលកោសល្យវិច្ច័យ នៃសារធាតុញៀនថាតើមានកំរិតធាតុសុទ្ធឲ្យបានច្បាស់លាស់ និងសុំប្រធានក្រុមប្រឹក្សាសម្រេចតាមច្បាប់ ។

-មេធាវីលោក [redacted] ការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា៖ចំពោះកូនក្តីខ្ញុំ [redacted] និង [redacted] ពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ថ្ងៃកើតហេតុកូនក្តីខ្ញុំឈ្មោះ [redacted] គ្រាន់តែទៅលេងកូនដូចពេលដងក្រសួមត្ថកិច្ចចាប់ខ្លួនតែម្តង កូនក្តីខ្ញុំឈ្មោះ [redacted] បានលែងលះគ្នាជាមួយឈ្មោះ [redacted] រស់នៅបែកគ្នាយូរហើយ ហើយពុំមានការពាក់ព័ន្ធអ្វីទេ សូម្បីតែទ្រព្យសម្បត្តិក៏គ្មានដែរ ។ ចំណែកឈ្មោះ [redacted] គ្រាន់តែជាជនរងគ្រោះជក់គ្រឿងញៀនតែប៉ុណ្ណោះ មិនដឹងរឿងរបស់ម្ចាស់ផ្ទះរកស៊ីគ្រឿងញៀនទេ យោងមាត្រា៣៨ រដ្ឋធម្មនុញ្ញ សុំលើកលែងចោទប្រកាន់ដល់កូនក្តីខ្ញុំ [redacted] និង [redacted] ។ ចំពោះកូនក្តីខ្ញុំឈ្មោះ [redacted] , [redacted] និង [redacted] គាត់បានសារភាពហើយ សុំប្រធានក្រុមប្រឹក្សាមេត្តាបន្ធូរបន្ថយទោស ព្រោះគ្រឿងញៀននោះពុំច្រើនទេ ហើយការប្រព្រឹត្តនោះដោយសារចាញ់បោក និងការអូសទាញរបស់ [redacted] ដែរ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងឯកសារនានា

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

**<u>សាលាឧទ្ធរណ៍</u>**

**<u>យល់ឃើញថា</u>**

១.ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៧៥១ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] បណ្តឹងឧទ្ធរណ៍លេខ ៧៤៩ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] បណ្តឹងឧទ្ធរណ៍លេខ ៧៣៤ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] បណ្តឹងឧទ្ធរណ៍លេខ ៧៣៣ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] បណ្តឹងឧទ្ធរណ៍លេខ ៧៣០ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២១៤ (ក្រ៤) ក.ព.ព្រ.ទ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន ។



Scanned by CamScanner

២.នាពេលសវនាការឈ្មោះ [redacted] បានឆ្លើយថា៖ខ្លួនជាអ្នករត់ម៉ូតូឌុបស្គាល់ឈ្មោះ [redacted] ប្រើខ្លួនឲ្យទៅយកឥវ៉ាន់ពីឈ្មោះ [redacted] នៅម្តុំពោធិ៍ចិនតុងចំនួន៣ដង ពុំដឹងថាឥវ៉ាន់នោះរបស់អ្វីទេ គេដាក់ថង់ខ្មៅខ្លួនស្មានថានំ ពុំដឹងថាគ្រឿងញៀនទេ ពេលយកមក [redacted] ឲ្យប្រាក់ខ្លួន១០០០០រៀល ទៅ ២០០០០រៀល ។ ជញ្ជីងថ្លឹងគ្រឿងញៀន ឧបករណ៍ជក់គ្រឿងញៀន និងគ្រឿងញៀនដែលសមត្ថកិច្ចដកហូតនេះជារបស់ [redacted] ពុំមែនជារបស់ខ្លួនទេ ។ ចម្លើយបដិសេធរបស់ជនជាប់ចោទពុំមានភស្តុតាងដោះបន្ទុកអាចឲ្យជឿបានទេ ព្រោះថា នៅចំពោះមុខសមត្ថកិច្ចឈ្មោះ [redacted] បានឆ្លើយសារភាពច្បាស់ថា ខ្លួនពិតជាបានយកគ្រឿងញៀនពីឈ្មោះ [redacted] ចំនួន៨ដង ឲ្យឈ្មោះ [redacted] និងទទួលប្រាក់ថ្លៃឈ្នួល២០០០០រៀល ។ ហើយតាមចម្លើយដាក់បន្ទុករបស់ [redacted] ជាគ្រឿងញៀន និងជញ្ជីងថ្លឹងគ្រឿងញៀនដែលសមត្ថកិច្ចដកហូតគឺជារបស់ [redacted] ។

៣.ជនជាប់ចោទ [redacted] បានឆ្លើយបដិសេធថាគ្រឿងញៀនដែលសមត្ថកិច្ចដកហូតនេះពុំដឹងរបស់អ្នកណាទេ ខ្លួនពុំជាប់ពាក់ព័ន្ធឡើយ ។ ខ្លួនបានលែងលះជាមួយ [redacted] យូរហើយ ពីបីថ្ងៃទៅផ្ទះ [redacted] ដើម្បីទៅមើលកូនថ្ងៃកើតហេតុពេលសមត្ថកិច្ចចុះឆែកឆេរផ្ទះរបស់ [redacted] គាប់ជួនពេលនោះខ្លួនជិះម៉ូតូទៅដល់បានសុំគេចូលទៅក្នុងផ្ទះ សមត្ថកិច្ចចាប់ខ្លួន ។ ពេលខ្លួនចូលទៅគឺសមត្ថកិច្ចបានឆែកឆេរ និងចាប់គ្រឿងញៀនយករួចហើយ ។ ពីមុនមកពុំធ្លាប់រកស៊ីគ្រឿងញៀនជាមួយ [redacted] ទេ ។ កាំភ្លើងរបស់ខ្លួនមានលិខិតបេសកកម្មត្រឹមត្រូវ ចម្លើយដោះសាររបស់ [redacted] ពុំអាចឲ្យតុលាការជឿបានទេព្រោះការលើកឡើងថា បានលែងលះឈប់រស់នៅជាមួយ [redacted] គ្មានភស្តុតាងបញ្ជាក់ ម្យ៉ាងទៀតប្រសិនបើ [redacted] ពុំមានការពាក់ព័ន្ធទេ ពេលសមត្ថកិច្ចកំពុងតែប្រតិបត្តការណ៍ឆែកឆេរបង្ក្រាបបទល្មើស ច្បាស់ជាសមត្ថកិច្ចពុំអនុញ្ញាតិឲ្យចូលទៅកន្លែងកើតហេតុឡើយ ។ ប៉ុន្តែជនជាប់ចោទក៏បានឆ្លើយនៅសមត្ថកិច្ច និងពេលសវនាការនេះសារភាពថា៖ខ្លួនបានរស់នៅជា ប្តីប្រពន្ធជាមួយ [redacted] តាំងពីឆ្នាំ២០០៩ ដល់២០១៣ ប្រពន្ធខ្លួនតែងតែរកស៊ីមានការលាក់លៀមជាមួយខ្លួន, ក្នុងខែសីហាឆ្នាំ២០១៣ ខ្លួនមានការសង្ស័យប្រពន្ធរកស៊ីគ្រឿងញៀន ព្រោះឃើញក្រាមសថ្លាទកញ្ចប់តូចនៅលើឡៅតឿ ។ ចម្លើយរបស់ [redacted] បានសារភាពនៅគ្រប់ដំណាក់កាលថាខ្លួនពិតជាបានរកស៊ីជួញដូរគ្រឿងញៀនតាំងពីខែធ្នូ ឆ្នាំ២០១៣ មកហើយ គ្រឿងញៀននេះខ្លួនទិញពីឈ្មោះ [redacted] ហើយពេលអ្នកជក់គ្រឿងញៀនមកទិញ និងជក់នៅផ្ទះរបស់ខ្លួនតាមអង្គហេតុនេះពេលសមត្ថកិច្ចចុះបង្ក្រាបដកហូតថ្នាំញៀន ឧបករណ៍សម្រាប់ជក់ និង ជញ្ជីងថ្លឹងថ្នាំញៀន និងគ្រឿងញៀន គឺស្របគ្នានឹងចម្លើយ [redacted] សារិន ថាប្រពន្ធខ្លួនសង្ស័យរកស៊ីជួញដូរគ្រឿងញៀនតាំងពីឆ្នាំ២០១៣ តែពុំបានចូល



Scanned by CamScanner

រួមជួញដូរជាមួយនោះពុំពិតទេ ព្រោះផ្ទះរបស់[redacted]កន្លែងដោះដូរ និងប្រើប្រាស់ផង ហេតុនេះ[redacted]ជាប្តីពិតជាបានដឹង និងជាអ្នកចូលរួមក្នុងការជួញដូរគ្រឿងញៀនពិតប្រាកដ ។ ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ[redacted] ថា ខ្លួនជាក្មួយ[redacted]បានហៅឲ្យមករស់នៅជាមួយ ខ្លួនធ្លាប់យកគ្រឿងញៀនពី [redacted]ទៅលក់បាន២ ទៅ៣ ដង ចំណេញពី១០ទៅ២០ ដុល្លា ។ ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ[redacted]ថា ខ្លួនមករស់នៅផ្ទះ[redacted] ស្គាល់គ្នានៅកាស៊ីណូណាហ្គាវើល គាត់បានហៅឲ្យខ្លួនឲ្យមកជួយមើលកូនឲ្យគាត់ដោយឲ្យឈ្នួល ១០ ទៅ២០ដុល្លា ក្នុង១សប្តាហ៍ ខ្លួនពិតជាបានយកគ្រឿងញៀនពី [redacted]ទៅលក់បន្តឲ្យមិត្តភ័ក្រ្ត ២ ទៅ៣ដង ចំណេញបានពី៥ដុល្លា ទៅ១០ដុល្លា ខ្លួនប្រើប្រាស់គ្រឿងញៀនជាមួយមិត្តភ័ក្រ្តជួនកាលនៅផ្ទះរបស់[redacted] ជួនកាលប្រើប្រាស់នៅក្រៅផ្ទះ ។ ចម្លើយសារភាពរបស់ជនជាប់ចោទ[redacted] និង[redacted]មានភស្តុតាងដាក់បន្ទុកស៊ីសង្វាក់ ហើយពេលសមត្ថកិច្ចចុះបង្ក្រាបបទល្មើសនោះក៏បានដកហូតគ្រឿងញៀនដែរហេតុនេះ ជនជាប់ចោទទាំងពីរនាក់ជាបក្ខពួក[redacted] ចម្លើយបដិសេធរបស់ជនជាប់ចោទឈ្មោះ[redacted]ថា៖ ខ្លួនពុំដែលជួយលក់គ្រឿងញៀនឲ្យ[redacted] ។ [redacted]បានហៅខ្លួនឲ្យមកជួយមើលកូនឲ្យថ្លៃឈ្នួល១សប្តាហ៍២០ដុល្លា ខ្លួនទទួលស្គាល់ប្រើប្រាស់គ្រឿងញៀន ចម្លើយដោះសារពុំអាចឲ្យជឿបានទេ ព្រោះតាមអង្គហេតុនេះ [redacted]ដូចជា[redacted] និង[redacted]ដែរ គឺ[redacted]បានហៅឲ្យមកនៅផ្ទះជាមួយខ្លួន ហើយ[redacted]ធ្លាប់លក់គ្រឿងញៀន៣ ទៅ៤ដង ដូចគ្នា ហេតុនេះ[redacted]ពិតជាអ្នកទិញគ្រឿងញៀនពី[redacted] ទៅលក់បន្តដើម្បីបានចំណេញ តាមចម្លើយរបស់[redacted]ថា ឈ្មោះ[redacted]បានទិញគ្រឿងញៀនបបួលខ្លួនប្រើប្រាស់៤លើកហើយ បើសិនជាឈ្មោះ[redacted] ពុំបានរកស៊ីលក់ដូរគ្រឿងញៀន ពុំអាចមានប្រាក់ទិញគ្រឿងញៀនចែកចាយឲ្យមិត្តភ័ក្រ្តប្រើប្រាស់ទេ ។

៤.សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ៖ ការឆ្លើយដោះសាររបស់ជនជាប់ចោទ [redacted]មានភស្តុតាងដោះបន្ទុកបញ្ជាក់ពីការលែងលះប្រពន្ធ [redacted]ទេ ជនជាប់ចោទឈ្មោះ[redacted] ពិតជាមានទំនាក់ទំនងរកស៊ីគ្រឿងញៀនជាមួយប្រពន្ធឈ្មោះ [redacted]ព្រោះផ្ទះជួលរបស់ [redacted]មានការទិញលក់ និងប្រើប្រាស់គ្រឿងញៀន ពេលសមត្ថកិច្ចឆែកឆេរ [redacted]ក៏នៅទីនោះដែរ ។ តាមអង្គហេតុនេះជនជាប់ចោទទាំងអស់គ្នាពិតជាបានទំនាក់ទំនងគ្នារកស៊ីទិញលក់គ្រឿងញៀនជាមួយគ្នា តែរយៈពេលទណ្ឌកម្មដែលសាលាដំបូងបានសម្រេចនោះ ធ្ងន់ធ្ងរពេកសុំតុលាការញែកឲ្យច្បាស់លាស់អំពីទំហំនៃការទទួលខុស



Scanned by CamScanner

ត្រូវរបស់ជនជាប់ចោទម្នាក់ៗ និងបញ្ជាក់ឲ្យច្បាស់លាស់ក្នុងសេចក្តីសម្រេចពីសារធាតុញៀនសុទ្ធ គប្បីពិចារណា ។

៥.មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទសុំឲ្យកូនក្តីខ្លួនឈ្មោះ [redacted] និង [redacted] រួចខ្លួនពីបទចោទប្រកាន់ថាពុំមានការពាក់ព័ន្ធនោះ សាលាឧទ្ធរណ៍យល់ឃើញថាៈពុំមានភស្តុតាងដោះបន្ទុកគប្បីបដិសេធចោល ។ ចំពោះការសុំឲ្យសំរាលទោសលើជនជាប់ចោទនោះឃើញថា [redacted], [redacted] ការសម្រេចអំពីទោសរបស់សាលាដំបូងរាជធានីភ្នំពេញត្រឹមអប្បរមានៃទោស រួចហើយចំពោះឈ្មោះ [redacted] គឺជាមេក្លោងហេតុនេះពុំពិចារណាបានទេ ហើយ [redacted] ានចរិកវៃរូសពុំសារភាព ។

៦.ទទួលស្គាល់កំហុសរបស់ខ្លួនគ្រឿងញៀនដែលសមត្ថកិច្ចដកហូតបាន ក.ក្រាមពណ៌សថ្លាប្រភេទមេតំហ្វេតាមីន ២៤៨,១៨ក្រាម តាមលទ្ធផលកោសល្យវិច្ច័យរបស់អាជ្ញាធរជាតិមានសារធាតុញៀនបញ្ជាក់ថាភាពសុទ្ធមេតំហ្វេតាមីន៧០,២១% ហេតុនេះ សារធាតុញៀនមេតំហ្វេតាមីនសុទ្ធគឺ ២៤៨,១៨ក្រាម គុណនឹង៧០,២១% ចែកនឹង១១០ ស្មើនឹង១៧៤,២៤ក្រាម ។ ខ. ថ្នាំគ្រាប់ពណ៌ផ្កាឈូកប្រភេទមេតំហ្វេតាមីនចំនួន១៣២គ្រាប់ ទំងន់១២,៨៥ក្រាម មានសារធាតុញៀនមេតំហ្វេតាមីនមានភាពសុទ្ធ១៤,០៥% ហេតុនេះសារធាតុញៀនសុទ្ធគឺ ១២,៨៥ ក្រាម គុណ នឹង ១៤,០៥% ចែកនឹង១០០ ស្មើនឹង១,៨០ក្រាម ។ គ.ម្សៅពណ៌ស ទំនង់២,៧៨ក្រាម ប្រភេទកាក្វអ៊ីនមានកំរិតសារធាតុញៀនសុទ្ធ ៤៦,២៤% ហេតុនេះសារធាតុញៀនកាក្វអ៊ីនសុទ្ធគឺ២,៧៨ក្រាម គុណ នឹង ៤៦,២៤ ចែកនឹង១០០ ស្មើនឹង១,២៨ក្រាម សរុបសារធាតុញៀនសុទ្ធទាំងបីមុខគឺមានទម្ងន់១៧៧,៣២ក្រាម ។ ផ្អែកតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ទណ្ឌកម្មដាក់ពន្ធនាគារពី១០ឆ្នាំ ទៅ ២០ឆ្នាំ កាលណាសារធាតុញៀនសុទ្ធមានទំងន់ពី ៨០ ក្រាមទៅ ២៨០ក្រាម ។ ចំពោះការស្នើរបស់មហាអយ្យការឲ្យញែកអំពីទណ្ឌកម្មលើជនជាប់ៈចោទម្នាក់ៗនោះ តាមអង្គហេតុនេះឈ្មោះ [redacted] និងឈ្មោះ [redacted] គឺមេក្លោងយកគ្រឿងញៀនមកឲ្យបក្ខពួកខ្លួន [redacted] ជាអ្នកលក់បន្ត ចំនួនគ្រឿងញៀនទាំងអស់នោះ គឺជាកម្មវត្ថុប្រព្រឹត្តបទល្មើស ដែលជាបក្ខពួកសម្រាប់លក់បន្តគឺជាការទទួលខុសត្រូវរួមជាមួយគ្នា ។

៧.ជនជាប់ចោទឈ្មោះ [redacted] បានដកពាក្យបណ្តឹងឧទ្ធរណ៍ ហើយសាលាឧទ្ធរណ៍បានសម្រេចតាមសាលដីកាព្រហ្មទណ្ឌលេខ២១ ក្រIV សស ចុះថ្ងៃទី០៤ ខែមិនា ឆ្នាំ២០១៥ រួចហើយ ហេតុនេះពុំពិចារណាទៀតទេ ។



Scanned by CamScanner

៨.សាលក្រមព្រហ្មទណ្ឌលេខ ២១៨ (ក្រ៨ក) ភ.ព.ព្រ.ទ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ បានលើកយកសំអាងហេតុ និងបានសម្រេចសេចក្ដីមានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ គប្បីតំកល់ទុកជាបានការ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១.ទទួលពាក្យបណ្ដឹងឧទ្ធរណ៍លេខ ៧៥១ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់តែបដិសេធចោលដោយទាស់និងគតិច្បាប់ ។

ទទួលពាក្យបណ្ដឹងឧទ្ធរណ៍លេខ ៧៤៩ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់តែបដិសេធចោលដោយទាស់និងគតិច្បាប់ ។

ទទួលពាក្យបណ្ដឹងឧទ្ធរណ៍លេខ ៧៣៤ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់តែបដិសេធចោលដោយទាស់និងគតិច្បាប់ ។

ទទួលពាក្យបណ្ដឹងឧទ្ធរណ៍លេខ ៧៣៣ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] កជាត្រឹមត្រូវតាមទម្រង់ច្បាប់តែបដិសេធចោលដោយទាស់និងគតិច្បាប់ ។

ទទួលពាក្យបណ្ដឹងឧទ្ធរណ៍លេខ ៧៣០ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់តែបដិសេធចោលដោយទាស់និងគតិច្បាប់ ។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២១៨ (ក្រ៨) ភ.ព.ព្រ.ទ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការទាំងមូលដដែល ។

៣.បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់ ។

សាលដីកានេះជំនុំជម្រះនាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥ និងប្រកាសជាសាធារណៈនៅសាលសវនាការនៃសាលាឧទ្ធរណ៍ នាថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៥ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារឲ្យជនជាប់ចោទ ។

បើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
| --- | --- | --- |
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

បានឃើញ
ក្រឡាបញ្ជីសាលាឧទ្ធរណ៍

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៥
ក្រឡាបញ្ជី

[redacted]



Scanned by CamScanner